# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច

## I. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ដល់ការងារអភិវឌ្ឍន៍លើគ្រប់វិស័យដោយបានដាក់ចេញនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានាជាច្រើន ដាក់ស្តែងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ដែលមាន១០វិស័យសំខាន់ៗ មានដូចជាវិស័យវប្បធម៌ វិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យសុខាភិបាល វិស័យបរិស្ថាន វិស័យដីធ្លី វិស័យកសិកម្ម និងធនធានទឹក វិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យយុត្តិធម៌ វិស័យទេសចរណ៍ វិស័យឧស្សាហកម្ម និងថាមពល ។ ក្នុងរយៈពេល២ឆ្នាំមកនេះ ទោះជាមានការរីករាលដាលកូវីត-១៩ យ៉ាងណាក៏ដោយនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច ក្រសួងអភិវឌ្ឍន៍ជនបទបាននឹងកំពុងខិតខំប្រឹងប្រែងបំពេញបេសកកម្មចំបងៗ របស់ខ្លួនក្នុងការផ្សារភ្ជាប់កិច្ចការអភិវឌ្ឍន៍ និងអភិរក្សដល់សហគមន៍ជនជាតិដើមភាគតិច ការចុះកំណត់អត្តសញ្ញាណ និងការបន្តផ្សព្វផ្សាយគោលនយោបាយជាតិជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការចូលរួមការពារសិទ្ធិ ការពារផលប្រយោជន៍ នឹងឈានទៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ឱ្យកាន់តែមានភាពប្រសើរឡើង ព្រមទាំងថែរក្សាបាននូវវប្បធម៌ប្រពៃណីល្អ ទំនៀមទម្លាប់របស់ពួកគាត់ ក្នុងន័យសំដៅរួមចំណែកកសាងមូលដ្ឋានគ្រឹះសង្គមជនបទស៊ីវិល័យឆ្នាំ២០២២-២០៣០។

## II. សមិទ្ធផលសម្រេចបាន

❖ នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច បានខិតខំសម្រេចភារកិច្ចរបស់ខ្លួន ដោយយកចិត្តទុកដាក់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដែលទទួលបានលទ្ធផលជាវិជ្ជមាន ដោយបានរៀបចំកិច្ចប្រជុំស្តីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច កួយ ចំនួន០៤ភូមិ នៅភូមិមន ភូមិទាល់ ភូមិផ្អាវ ភូមិស្តង់ ឃុំអន្លង់ជ្រៃ ឃុំអន្លង់ភេ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

❖ រៀបចំកិច្ចប្រជុំស្តីពី ការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព័រ និងជង ចំនួន ០២ភូមិ នៅភូមិអូរព្រាល និងភូមិតាដែស ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ រៀបចំកិច្ចប្រជុំស្តីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ស្អូច ចំនួន ១ភូមិ នៅភូមិសំរុងលើ ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

❖ អនុម័តលើខ្លឹមសារសេចក្តីព្រាងបទបញ្ញាផ្ទៃក្នុងសហគមន៍ជនជាតិដើមភាគតិច កាចក់

និងគ្រឹង ចំនួន ៤ភូមិ ក្នុងការប្រើប្រាស់ចាត់ចែង ការគ្រប់គ្រងតាមបែបប្រពៃណី ទំនៀមទម្លាប់ ដូនតារបស់ពួកគាត់ នៅភូមិកាក់ ឃុំតាឡាវ ស្រុកអណ្ដូងមាស និងភូមិចាន់ ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី

❖ បានរៀបចំសិក្ខាសាលាតម្រង់ទិសស្ដីពី នីតិវិធីនៃការវាយតម្លៃកំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិច និងបូកសរុបការងារជាមួយអង្គការដៃគូអភិវឌ្ឍន៍ ក្នុងគោលបំណងប្រមូលធាតុចូលទៅក្នុងផែនការសកម្មភាពការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិចក្នុងឆ្នាំ២០២៣

❖ បានរៀបចំកិច្ចប្រជុំជាមួយមន្ទីរក្នុងខេត្តគោលដៅទាំង ១៥ខេត្ត ស្ដីពីផែនការសកម្មភាពការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិច ក្រោមអធិបតីភាព **ឯកឧត្តម សួន សេរីរដ្ឋា** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ

❖ បានចុះជួបពិភាក្សាការងារ អំពីលទ្ធភាពជំរុញការចុះកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ជង នៅស្រុកថ្មបាំង ខេត្តកោះកុង

❖ ដឹកនាំក្រុមការងារចុះជួបជាមួយថ្នាក់ដឹកនាំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី ក្នុងគោលបំណងជួបសំណេះសំណាលពិភាក្សាការងារដើម្បីពន្លឿនការកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរី

❖ បានរៀបចំកិច្ចប្រជុំស្ដីពី ការងារអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិចប្រចាំឆមាសទី១ រវាងនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច និងមន្ទីរអភិវឌ្ឍន៍ជនបទទាំង ១៥ខេត្ត ជាលទ្ធផល មន្ទីរអភិវឌ្ឍន៍ជនបទទាំង ១៥ខេត្ត បានរាយការណ៍អំពីការងារអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងបានលើកឡើងពីសមិទ្ធផលដែលមន្ទីរនីមួយៗសម្រេចបាន លើកទិសដៅការងារបន្ត បញ្ហាប្រឈម និងសំណូមពរ

❖ ចូលរួមកិច្ចប្រជុំពេញអង្គ ដើម្បីពិនិត្យ និងអនុម័តលើខ្លឹមសារព្រាងបទបញ្ជាផ្ទៃក្នុង ស្ដីពីការគ្រប់គ្រង ប្រើប្រាស់ដី និងធនធានធម្មជាតិសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិពែង ឃុំញ៉ាង ស្រុកអណ្ដូងមាស និងសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិអ៊ីន ឃុំតាឡាវ ស្រុកអណ្ដូងមាស ខេត្តរតនគិរី

❖ ចូលរួមកិច្ចប្រជុំពេញអង្គ ដើម្បីពិនិត្យ និងអនុម័តលើខ្លឹមសារព្រាងបទបញ្ជាផ្ទៃក្នុង ស្ដីពីការគ្រប់គ្រង ប្រើប្រាស់ដី និងធនធានធម្មជាតិសហគមន៍ជនជាតិដើមភាគតិច គ្រឹង នៅភូមិចាន់ ឃុំតាវែងលើ ស្រុកតាវែង និងសហគមន៍ជនជាតិដើមភាគតិច កាចក់ នៅភូមិកាក់ ឃុំតាឡាវ ស្រុកអណ្ដូងមាស ខេត្តរតនគិរី

## III. **បញ្ហាប្រឈម**

❖ ថវិកាជាតិនៅមានកម្រិតក្នុងការអនុវត្តដំណើរការ កំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច

❖ គម្លាតកិច្ចសហការរវាងនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមួយចំនួន និងបណ្ដាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសព្រមទាំងដៃគូអភិវឌ្ឍន៍

❖ សមត្ថភាពមន្ត្រីនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទមួយចំនួននៅមានកម្រិត

- ❖ ការចូលរួមរបស់បងប្អូនជនជាតិដើមភាគតិចនៅមានកម្រិត
- ❖ បងប្អូនជនជាតិដើមភាគតិចធ្វើការចំណាកស្រុកច្រើន
- ❖ បងប្អូនជនជាតិដើមភាគតិចមួយចំនួនលាក់អត្តសញ្ញាណរបស់ខ្លួន
- ❖ ដំណើរការនៃការកំណត់អត្តសញ្ញាណមានភាពយឺតយ៉ាវ មិនអាចឆ្លើយតបទៅនឹងគោល នយោបាយរបស់រាជរដ្ឋាភិបាល ។

## IV. **ទិសដៅការងារឆ្នាំ ២០២៣**

❖ ពន្លឿនក្នុងការចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចឲ្យបានយ៉ាងតិចចំនួន ១៣ ភូមិ និងសម្របសម្រួលរៀបចំបទបញ្ជាផ្ទៃក្នុងសហគមន៍ចំនួន ២០ភូមិ

❖ ចុះកំណត់សហគមន៍គោលដៅ និងផ្សព្វផ្សាយស្តីពីគោលនយោបាយជាតិ ច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគិត្តិយុត្តិ ចំនួន ១៣ សហគមន៍ជនជាតិដើមភាគតិចត្រូវបានផ្សព្វផ្សាយស្តីពីគោលនយោបាយជាតិ ច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគិត្តិយុតិ នៅខេត្តស្ទឹងត្រែង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តមានជ័យ និងខេត្តពោធិសាត់

❖ បន្តចុះសិក្សាភូមិគោលដៅបន្ថែមទៀត ដើម្បីរៀបចំចុះវាយតម្លៃកំណត់អត្តសញ្ញាណ

❖ ចុះរៀបចំកំណត់ទីតាំងភូមិសាស្ត្រគោលរបស់សហគមន៍ជនជាតិដើមភាគតិចនៅខេត្ត និងសហគមន៍គោលដៅ ចំនួន០៤ខេត្ត និង០៧សហគមន៍

❖ ចុះកំណត់ទីតាំងភូមិសាស្ត្រគោលដើម្បីរៀបចំផែនទីសម្រាប់សហគមន៍ជនជាតិដើមភាគតិច ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តក្រចេះ

❖ ប្រជុំប្រកាសស្វ័យអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ឲ្យបានយ៉ាងតិចចំនួន១៣ សហគមន៍នៅខេត្តស្ទឹងត្រែង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តមានជ័យ និងខេត្តពោធិ៍សាត់

❖ ចុះផ្សព្វផ្សាយអំពីច្បាប់ គោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្តិ ដល់មន្ទីរជំនាញពាក់ព័ន្ធ អាជ្ញាធរខេត្ត ស្រុក ឃុំ និងតំណាងជនជាតិដើមភាគតិច ។

❖ រៀបចំអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិច ពិភពលោកលើកទី២៩ និងលើកទី ១៩ នៅកម្ពុជាចំនួន០១ លើកដោយមានចំនួនអ្នកចូលរួមសរុបប្រមាណ១២០០នាក់ នៅខេត្តបាត់ដំបង

❖ រៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ខេត្ត ចំនួន ០២វគ្គ ដោយមានអ្នកចូលរួមសរុបប្រមាណ ១៧០នាក់ ខេត្តព្រះវិហារ និងខេត្តរតនគិរី ។

## V. **សេចក្តីសន្និដ្ឋាន**

ដោយសារបរិបទកូវីដ-១៩ទើបបានធូរស្រាល នៅក្នុងឆ្នាំ២០២២នេះ នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច បានទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចបានចំនួន ០៥សហគមន៍បន្ថែមទៀត។ជាលទ្ធផលគិតត្រឹមឆ្នាំ២០២២នេះ នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច បានទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចសរុបបានចំនួន ១៦០សហគមន៍ ។ សមិទ្ធផលផ្សេងទៀតដូចជាការរៀបចំសិក្ខាសាលា ការរៀបចំទិវាជនជាតិដើមភាគតិច ការរៀបចំបទបញ្ជាផ្ទៃក្នុង ការងារទាំងអស់នេះ សុទ្ធតែបានចូលរួមលើកកម្ពស់សិទ្ធិជនជាតិដើមភាគតិច ដែលស្របទៅនឹងច្បាប់ភូមិបាលឆ្នាំ២០០១ ។ គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍ ការគាំទ្រផ្នែកថវិកា

របស់រដ្ឋាភិបាលជាចំណុចសំខាន់ដែលជំរុញឱ្យនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច មានលទ្ធភាពក្នុងការបន្តចុះកំណត់អត្តសញ្ញាណដែលនៅប្រមាណ ២៩៥ភូមិគោលដៅទៀត ដើម្បីប្រាកដថា ភូមិជនជាតិដើមភាគតិចទាំងអស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានទទួលស្គាល់ជាផ្លូវការដោយក្រសួងអភិវឌ្ឍន៍ជនបទ មុននឹងរៀបចំឆ្ពោះទៅការងារអភិរក្ស និងអភិវឌ្ឍន៍នាពេលខាងមុខ។